# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ៤១ ក.ធ.ស/ប្រ

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែ មីនា ឆ្នាំ ២០០៧

លិខិតចូល
ថ្ងៃទី២០ ខែ៣ ឆ្នាំ2007

## ប្រកាស

## ស្តីពីការបង្កើតសាលាពុទ្ធិកអនុវិទ្យាល័យកៀនស្វាយ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ នឹងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ-បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ នឹងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងតាមចំណារបញ្ជូនលេខ ០១៣ ធ.ក.ខ ចុះថ្ងៃទី០៥ ខែកុម្ភៈឆ្នាំ២០០៧ របស់មន្ទីរធម្មការ និង សាសនាខេត្តកណ្តាល
- យោងតាមចំណារបញ្ជូនលេខ ១១១ ស.ណ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០០៧ របស់អភិបាលខេត្តកណ្តាល
- យោងតាមការចាំបាច់របស់អធិការដ្ឋានពុទ្ធិកសិក្សា ដើម្បីអភិវឌ្ឍន៍ពុទ្ធិកសិក្សា

## សំរេច

**ប្រការ ១ :** ត្រូវបានបង្កើតសាលា **ពុទ្ធិកអនុវិទ្យាល័យកៀនស្វាយ** ដែលមានទីតាំងនៅក្នុង វត្តមុនីសាគរ ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

**ប្រការ ២ :** សាលាពុទ្ធិកអនុវិទ្យាល័យ **កៀនស្វាយ** ជាគ្រឹះស្ថានពុទ្ធិកសិក្សា ស្ថិតនៅក្រោមការដឹកនាំរបស់មន្ទីរ ធម្មការ និង សាសនា ខេត្តកណ្តាល និងការណែនាំមុខជំនាញបច្ចេកទេស របស់អគ្គាធិការដ្ឋាន ពុទ្ធិកសិក្សាជាតិ នៃក្រសួងធម្មការ និង សាសនា ។

**ប្រការ ៣ :** សាលាពុទ្ធិកអនុវិទ្យាល័យនេះ ត្រូវអនុវត្តដំណើរការសិក្សា ពីឆ្នាំសិក្សា ២០០៧-២០០៨ តទៅ ។

**ប្រការ ៤ :** រាល់សេចក្តីប្រកាសទាំងឡាយណាដែលផ្ទុយពីសេចក្តីប្រកាសខាងលើនេះ ទុកជានិរាករណ៍ ។

**ប្រការ ៥ :** អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ការិយាល័យបុគ្គលិកមន្ទីរធម្មការ និងសាសនាខេត្តកណ្តាល មានភារកិច្ចរៀងៗខ្លួនអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា**

**ឃុន ហាំង**

**ចម្លងជូន :**

- សម្តេចព្រះអគ្គមហាសង្ឃរាជ
- សម្តេចគណៈព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងអប់រំយុវជន និងកីឡា
- ព្រះមេគណរាជធានីភ្នំពេញ

" ដើម្បីថ្វាយ-ប្រគេន-ជូនជ្រាបជាពតិមាន "

- ដូចប្រការ២ " ដើម្បីអនុវត្ត "
- រាជកិច្ចកិច្ច " ដើម្បីចុះផ្សាយ "
- ឯកសារ កាលប្បវត្តិ